**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ២១៣-០១៦ ធ.ជ.ក.កសណ

រាជធានីភ្នំពេញ ថ្ងៃទី១៤ខែមីនា ឆ្នាំ២០១៦

# សេចក្តីជូនដំណឹង
## អំពី
## ទិវាអបអរសាទរការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ លើកទី៣៦

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា នៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៦ ខាងមុខ ធនាគារជាតិនៃកម្ពុជាសហការជាមួយសមាគមសហគ្រិនវ័យក្មេងកម្ពុជា នឹងរៀបចំទិវាអបអរសាទរការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ លើកទី៣៦ នៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា ជប៉ុន-(CJCC) ។

គោលបំណងនៃការប្រារព្ធទិវានេះ គឺដើម្បីរំឭកខួបនៃការដាក់ឱ្យចរាចរប្រាក់រៀលឡើងវិញ ព្រមទាំងដើម្បីបង្ហាញការគាំទ្រ និងលើកទឹកចិត្តឱ្យវិស័យឯកជនបង្កើនការប្រើប្រាស់ប្រាក់រៀលនៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ខ្លួនដោយស្មារតីស្ម័គ្រចិត្ត ។ ទិវានេះក៏ជាវេទិកាដ៏សំខាន់មួយសម្រាប់វិស័យពាក់ព័ន្ធនានា ទាំងឯកជននិងសាធារណៈ ដើម្បីស្វែងយល់ពីសារៈសំខាន់នៃតួនាទីប្រាក់រៀលចំពោះសេដ្ឋកិច្ចនិងសង្គមជាតិ និងចូលរួមអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការប្រើប្រាស់ប្រាក់រៀល ។ ទិវានេះមានការអញ្ជើញចូលរួមពីតំណាងជាន់ខ្ពស់មកពីក្រសួង-ស្ថាប័ននានា គ្រឹះស្ថានហិរញ្ញវត្ថុ និងក្រុមហ៊ុន-សហគ្រាសឯកជននៅកម្ពុជា ។/

**អគ្គនាយកបច្ចេកទេស**

**ជា សិរី**

ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧